សុខភាព និងជីវិត
កាន់តែប្រសើរ



# គម្រោងការពារ សម្រាប់គ្រួសារ លើការសម្រាក ព្យាបាលក្នុងមន្ទីរពេទ្យ

## អត្ថប្រយោជន៍ប្រាក់ឧបត្ថម្ភសម្រាកក្នុងមន្ទីរពេទ្យ

យើងទាំងអស់គ្នាប្រាថ្នាចង់បានជីវិតដែលមានការការពារ សុភមង្គល និងសុខភាពល្អ ប៉ុន្តែយើងមិនអាចគ្រប់គ្រងអ្វីដែលនឹងកើតឡើងចំពោះយើងបានទេ។ តើអ្នកធ្លាប់គិតពីការរៀបចំហិរញ្ញវត្ថុសម្រាប់ខ្លួនអ្នក ឬកូនតូចៗរបស់អ្នក ក្នុងស្ថានភាពមិនបានព្រៀងទុកណាមួយដែលបង្កដោយគ្រោះថ្នាក់ចៃដន្យ ឬជំងឺណាមួយ ដែរឬទេ?

ថ្វីបើយើងមិនអាចជៀសផុតពីព្រឹត្តិការណ៍អកុសលទាំងនោះដែលនឹងអាចកើតឡើង ប៉ុន្តែយើងអាចរៀបចំជាមុន និងធានាឱ្យបានថាយើងទទួលបានការការពារផ្នែកហិរញ្ញវត្ថុគ្រប់គ្រាន់សម្រាប់គ្រួសារ ដែលជាជំនួយភ្លាមៗ ក្នុងករណីចាំបាច់ត្រូវសម្រាកព្យាបាលក្នុងមន្ទីរពេទ្យដែលបង្កដោយគ្រោះថ្នាក់ចៃដន្យណាមួយ ឬជំងឺផ្សេងៗ។

# តើអត្ថប្រយោជន៍ប្រាក់ឧបត្ថម្ភសម្រាកក្នុងមន្ទីរពេទ្យជាអ្វី?

ផលិតផលធានារ៉ាប់រងបន្ថែម "**អត្ថប្រយោជន៍ប្រាក់ឧបត្ថម្ភសម្រាកក្នុងមន្ទីរពេទ្យ**" ផ្តល់ប្រាក់ឧបត្ថម្ភជាសាច់ប្រាក់ទៅលើការចំណាយប្រចាំថ្ងៃលើការសម្រាកនៅក្នុងមន្ទីរពេទ្យ ថែមទាំងការ ផ្តល់ជូនក្នុងករណីសម្រាកព្យាបាលក្នុងបន្ទប់សង្គ្រោះបន្ទាន់ (ICU) ដែលបង្កដោយគ្រោះថ្នាក់ចៃដន្យ ឬជំងឺណាមួយ។

## អត្ថប្រយោជន៍សំខាន់ពិសេសៗ

ប្រាក់ឧបត្ថម្ភជាសាច់ប្រាក់ សម្រាប់ការសម្រាកក្នុងមន្ទីរពេទ្យដែលបង្កដោយគ្រោះថ្នាក់ចៃដន្យឬជំងឺផ្សេងៗ

- អត្ថប្រយោជន៍ប្រាក់ឧបត្ថម្ភសម្រាកក្នុងមន្ទីរពេទ្យ សម្រាប់ការសម្រាកព្យាបាលក្នុងបន្ទប់ទូទៅ **100%** នៃសាច់ប្រាក់ឧបត្ថម្ភប្រចាំថ្ងៃ
- អត្ថប្រយោជន៍ប្រាក់ឧបត្ថម្ភសម្រាកក្នុងមន្ទីរពេទ្យ សម្រាប់ការសម្រាកព្យាបាលក្នុងបន្ទប់សង្គ្រោះបន្ទាន់ (ICU) **300%** នៃសាច់ប្រាក់ឧបត្ថម្ភប្រចាំថ្ងៃ



## ឧទាហរណ៍៖

# រៀបចំគម្រោងទុកជាមុន ដើម្បីធានាដំណើរជីវិតដ៏ប្រសើរសម្រាប់កូនអ្នក

**លោកស្រី បុប្ផា** អាយុ 28 ឆ្នាំ ជាម្តាយដែលមានកូនប្រុសម្នាក់អាយុ 3 ឆ្នាំ ឈ្មោះ**សិទ្ធីស័ក្តិ** ។ លោកស្រីបានរៀបចំគម្រោងការការពារកូនរបស់គាត់ ជាមួយផលិតផលធានារ៉ាប់រងមូលដ្ឋាន "**AIA ការពារកូន**" ។ លើសពីនេះគាត់ក៏កំពុងស្វែងរកគម្រោងដែលផ្តល់ដំណោះស្រាយផ្នែកសុខភាព ដើម្បីជួយសម្រាលលើការចំណាយសម្រាកក្នុងមន្ទីរពេទ្យសម្រាប់កូនរបស់គាត់។ ដូច្នេះលោកស្រីបានសម្រេចចិត្តបន្ថែមការការពារជាមួយ ផលិតផលធានារ៉ាប់រងបន្ថែម "**អត្ថប្រយោជន៍ប្រាក់ឧបត្ថម្ភសម្រាកក្នុងមន្ទីរពេទ្យ**" ដោយភ្ជាប់ជាមួយគម្រោងផលិតផលមូលដ្ឋាន ដើម្បីប្រាកដថាកូនរបស់គាត់ទទួលបានការពារដ៏ពេញលេញក្នុងគម្រោងតែមួយ ជាមួយប្រាក់ឧបត្ថម្ភប្រចាំថ្ងៃសម្រាកក្នុងមន្ទីរពេទ្យចំនួន US$30/ថ្ងៃ។ លោកស្រីជ្រើសរើសរយៈពេលនៃការធានារ៉ាប់រងចំនួន 19 ឆ្នាំ ជាមួយនឹងការទូទាត់ បុព្វលាភធានារ៉ាប់រងរយៈពេល 15 ឆ្នាំ និងការបង់បុព្វលាភធានារ៉ាប់រងប្រចាំឆ្នាំចំនួន **US$110.30** (ទឹកប្រាក់បុព្វលាភធានារ៉ាប់រងនេះសម្រាប់តែផលិតផលធានារ៉ាប់រងបន្ថែមប៉ុណ្ណោះ)។

## អត្ថប្រយោជន៍ផ្តល់ជូនដល់ក្រុមគ្រួសារលោកស្រីបុប្ផា

ក្នុងករណីមានគ្រោះអកុសលណាមួយបានកើតឡើងចំពោះ សិទ្ធីស័ក្តិ ដែលបង្កឡើងគ្រោះថ្នាក់ ឬជំងឺណាមួយ ក្នុងរយៈពេលនៃបណ្ណសន្យារ៉ាប់រង គ្រួសារលោកស្រីបុប្ផា នឹងទទួលបានប្រាក់ឧបត្ថម្ភសម្រាកព្យាបាលក្នុងមន្ទីរពេទ្យ ដូចទៅនឹងករណីគំរូបង្ហាញខាងក្រោម៖

**ករណីទី 1: សិទ្ធីស័ក្តិ** បានកើតជំងឺគ្រុនឈាម ហើយតម្រូវឱ្យចូលសម្រាកព្យាបាលក្នុងមន្ទីរពេទ្យ នៅក្នុងបន្ទប់ទូទៅរយៈពេល 5 (ប្រាំ) ថ្ងៃ។

គ្រួសារ **លោកស្រីបុប្ផា** នឹងទទួលបានប្រាក់ឧបត្ថម្ភចំនួន **US$150 (US$30/ថ្ងៃ x 5 ថ្ងៃ)** ពីអត្ថប្រយោជន៍ប្រាក់ឧបត្ថម្ភសម្រាកក្នុងមន្ទីរពេទ្យ ជាជំនួយសម្រាប់ថ្លៃព្យាបាលនេះ។

**ករណីទី 2: សិទ្ធិស័ក្តិ** បានជួបគ្រោះថ្នាក់ដោយម៉ូតូបុក ហើយតម្រូវឲ្យចូលសម្រាកព្យាបាលក្នុងបន្ទប់សង្គ្រោះបន្ទាន់រយៈពេល 4 (បួន) ថ្ងៃ និងបន្តស្នាក់នៅបន្ទប់ទូទៅរយៈពេល 5 (ប្រាំ) ថ្ងៃទៀត ។

គ្រួសារ **លោកស្រីបុប្ផា** នឹងទទួលបានប្រាក់ឧបត្ថម្ភសរុបចំនួន **US$360 [(US$30/ថ្ងៃ x 3ដង)** x 4 ថ្ងៃ] សម្រាប់បន្ទប់សង្គ្រោះបន្ទាន់ រួមទាំងប្រាក់ឧបត្ថម្ភចំនួន **US$150 (US$30/ថ្ងៃ x 5 ថ្ងៃ)** សម្រាប់បន្ទប់ធម្មតា ជាការជួយសម្រាលបន្ទុកថ្លៃព្យាបាលជំងឺរបស់ **សិទ្ធីស័ក្តិ** ឱ្យបានទាន់ពេលវេលា។

# ព័ត៌មានសង្ខេបស្តីពីផលិតផល

- **អាយុចុះឈ្មោះដំបូង**
  30 ថ្ងៃ- 60 ឆ្នាំ
- **អាយុផុតកំណត់**
  70 ឆ្នាំ
- **រយៈពេលនៃការធានារ៉ាប់រង**
  ដូចគ្នាទៅនឹងរយៈពេលនៃការធានារ៉ាប់រងសម្រាប់ផលិតផលធានារ៉ាប់រងមូលដ្ឋានដែលភ្ជាប់ជាមួយ ដោយអនុលោមតាមអាយុរបស់អ្នកត្រូវបានធានារ៉ាប់រងអតិបរមាត្រឹមអាយុ 70 ឆ្នាំ។
- **រយៈពេលនៃការបង់បុព្វធានារ៉ាប់រង**
  ដូចគ្នាទៅនឹងរយៈពេលនៃការធានារ៉ាប់រងសម្រាប់ផលិតផលធានារ៉ាប់រងបន្ថែមនេះ ឬអនុលោមតាមរយៈពេលនៃការបង់បុព្វលាភធានារ៉ាប់រងសម្រាប់ផលិតផលធានារ៉ាប់រងមូលដ្ឋានដែលភ្ជាប់ជាមួយ។

## ការទាមទារសំណង

ប្រសិនបើអ្នក ចង់ធ្វើការទាមទារសំណង អ្នកត្រូវបំពេញទម្រង់បែបបទទាមទារសំណង និងផ្តល់ភស្តុតាង ក្នុង កំឡុងពេល 90 ថ្ងៃនៃថ្ងៃប្រតិទិន ពីការកើតឡើងនៃព្រឹត្តិការណ៍ដែលត្រូវបានធានារ៉ាប់រង។ អ្នកអាចទាញយកទម្រង់បែបបទទាមទារសំណង ពីគេហទំព័ររបស់យើង គឺ **aia.com.kh** ឬ ពីទីប្រឹក្សាផែនការជីវិត AIA ។

រាល់ឯកសារ និងភស្តុតាងចាំបាច់ដែលត្រូវដាក់ភ្ជាប់ជាមួយនឹងទម្រង់បែបបទទាមទារសំណងមកកាន់ក្រុមហ៊ុន AIA មានដូចជា វិក័យប័ត្រច្បាប់ដើម វិញ្ញាបនបត្រវេជ្ជសាស្ត្ររបាយការណ៍ចេញពីមន្ទីរពេទ្យ និងឯកសារវេជ្ជសាស្ត្រផ្សេងទៀត។ ក្នុងករណី កាលបរិច្ឆេទចូលសម្រាក និងកាលបរិច្ឆេទចេញពីមន្ទីរពេទ្យ គឺជាកាលបរិច្ឆេទតែមួយ នៅលើរបាយការណ៍ចេញពីមន្ទីរពេទ្យ ឬវិញ្ញាបនបត្រវេជ្ជសាស្ត្រត្រូវមានការបញ្ជាក់ពីកាលបរិច្ឆេទ និងពេលវេលាច្បាស់លាស់។ រាល់ឯកសារវេជ្ជសាស្ត្រទាំងអស់ ត្រូវតែចេញដោយ និងទទួលស្គាល់ពីមន្ទីរវេជ្ជសាស្ត្រដែលមានអាជ្ញាបណ្ណស្របច្បាប់លើការផ្តល់សេវាព្យាបាលវេជ្ជសាស្ត្រនៅក្នុងប្រទេស។

អ្នកទាមទារសំណងអាចស្នើសុំសំណង ប្រសិនបើករណីត្រូវទាមទារសំណង និងការព្យាបាលផ្នែកវេជ្ជសាស្ត្រកើតឡើងក្នុងកំឡុងពេលបណ្ណសន្យារ៉ាប់រងកំពុងមានសុពលភាព។

**ការទទួលយកសំណើធានារ៉ាប់រង**
សូមទាក់ទង ទីប្រឹក្សាផែនការជីវិត AIA ឬសេវាបម្រើអតិថិជន AIA Client Care

AIA CAMBODIA
TELEGRAM CHANNEL
SCAN TO REGISTER

**086 999 242 / 023 999 242,**
**kh.care@aia.com**
**aia.com.kh**
AIA Cambodia Telegram Channel

# ករណីមិនធានា

ផលិតផលធានារ៉ាប់រងបន្ថែមនេះមិនធានាលើការសម្រាកក្នុងមន្ទីរពេទ្យណាមួយដែលបង្កឡើងដោយផ្ទាល់ឬដោយប្រយោលទាំងស្រុង ឬដោយផ្នែក ដោយហេតុការណ៍ណាមួយខាងក្រោមឡើយៈ

1. ការបង្កឱ្យកើតអំពើហិង្សាលើរាងកាយ ឬឃាតកម្ម ឬ
2. កុបកម្ម និងចលាចល ឬភេរវកម្ម ឬ
3. សង្គ្រាមដែលបានប្រកាស ឬមិនបានប្រកាស ឬបដិវត្តន៍ ឬ
4. ការចូលបម្រើក្នុងជួរកងទ័ពក្នុងកំឡុងពេលមានប្រកាស ឬគ្មានប្រកាសសង្គ្រោមក្តី ឬក្រោមបញ្ជាប្រតិបត្តិការសង្គ្រាម ឬការស្តារសណ្តាប់ធ្នាប់សាធារណៈ ឬ
5. ការធ្វើអត្តឃាត ឬការប៉ុនប៉ងធ្វើអត្តឃាត ឬការធ្វើឱ្យរបួសខ្លួនឯងណាមួយ ទោះស្ថិតក្នុងស្ថានភាពផ្លូវចិត្តប្រក្រតី ឬមិនប្រក្រតីក៏ដោយ ឬ
6. ការចូលរួមក្នុងការធ្វើដំណើរតាមផ្លូវអាកាសលើកលែងតែអ្នកត្រូវបានធានារ៉ាប់រងជាអ្នកដំណើរធម្មតាក្នុងយន្តហោះពាណិជ្ជកម្មដែលបានចុះបញ្ជីការត្រឹមត្រូវ ឬ
7. ការរំលោភបំពាន ឬប៉ុនប៉ងរំលោភបំពានច្បាប់ ឬបដិសេធនឹងការចាប់ខ្លួន ឬ
8. ឧបទ្ទវហេតុដែលកើតឡើងខណៈពេលដែល ឬដោយសារអ្នកត្រូវបានធានាស្ថិតក្រោមឥទ្ធិពលជាតិស្រវឹង ឱសថដែលមិនបានចេញដោយវេជ្ជបញ្ជា ឬគ្រឿងញៀនខុសច្បាប់ផ្សេងៗ ឬ
9. ការសម្រាកក្នុងមន្ទីរពេទ្យដែលបណ្តាលមកពីស្ថានភាពមុនពេលធានារ៉ាប់រង ឬ
10. ការត្រួតពិនិត្យរាងកាយជាប្រចាំ និងការព្យាបាលសម្រាក ការស្តារនីតិសម្បទា និងការសម្រាកថែទាំក្នុងមន្ទីរពេទ្យ ឬ
11. ការចូលរួមក្នុងកីឡាអាជីពឬសកម្មភាពដែលមានគ្រោះថ្នាក់ដូចជាការហក់លោតពីទីអាកាសខ្ពស់(skydiving)ការលោតឆ័ត្រយោង (parachuting) ការលោតពីទីខ្ពស់ដោយប្រើខ្សែពួរ (bungee jumping) ការឡើងភ្នំ ប្រណាំង ការជ្រមុជទឹក (Scuba diving) ការប្រណាំងក្នុងទម្រង់ណាមួយ ឬ
12. ជំងឺផ្នែកសតិអារម្មណ៍ ឬផ្លូវចិត្ត ភាពខុសប្រក្រតីនៃផ្នែកប្រសាទ ឬភាពខុសប្រក្រតីនៃបញ្ហាផ្នែកដំណេកដែលបង្ហាញឱ្យឃើញ ឬផលវិបាកផ្សេងទៀតដែលកើតឡើងពីជំងឺទាំងនេះ ឬ
13. ជំងឺអេដស៍ ឬរោគសញ្ញារបស់ជំងឺអេដស៍ ឬការឆ្លងដោយវីរុសហ៊ីវ ឬ
14. ជំងឺឬពិការភាពពីកំណើតឬដោយមេរោគពីកំណើតដែលត្រូវបានពិនិត្យឬធ្វើរោគវិនិច្ឆ័យឃើញមុនពេលអ្នកត្រូវបានធានារ៉ាប់រងមានអាយុ 17 (ដប់ប្រាំពីរ) ឆ្នាំ លើកលែងតែអាការៈជំងឺដែលត្រូវបានប្រកាស និងត្រូវបានទទួលយកនៅពេលដាក់ពាក្យស្នើសុំ ឬ
15. ការសម្រាកក្នុងមន្ទីរពេទ្យ មុនកាលបរិច្ឆេទដែលបណ្ណសន្យារ៉ាប់រងមានសុពលភាព ឬកាលបរិច្ឆេទដែលចូលជាធរមាននៃផលិតផលធានារ៉ាប់រងបន្ថែមនេះ ដោយយកកាលបរិច្ឆេទណាមួយចុងក្រោយគេ ឬ
16. ការសម្រាកក្នុងមន្ទីរពេទ្យដែលបង្កដោយជំងឺ ក្នុងកំឡុងពេល 45 (សែសិបប្រាំ) ថ្ងៃនៃថ្ងៃប្រតិទិន គិតចាប់ពីកាលបរិច្ឆេទដែលបណ្ណសន្យារ៉ាប់រងមានសុពលភាពឬកាលបរិច្ឆេទដែលចូលជាធរមាននៃផលិតផលធានារ៉ាប់រងបន្ថែមនេះដោយយកកាលបរិច្ឆេទណាមួយចុងក្រោយគេ ឬ
17. រាល់ការសម្រាកព្យាបាលនៅមន្ទីរពេទ្យណាមួយដែលស្ថានភាពជំងឺ ឬចំនួនថ្ងៃនៃការសម្រាកព្យាបាលនៅមន្ទីរពេទ្យមិនមានភាពចាំបាច់ក្នុងការព្យាបាល ដូចដែលបានកំណត់ដោយក្រុមហ៊ុន។

**ការិយាល័យកណ្តាល**

អគារ ជីអាយអេ ថៅអឺរ ជាន់ទី31 ផ្លូវសុភមង្គល ភូមិ14 សង្កាត់ទន្លេបាសាក់
ខណ្ឌចំការមន រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

**សាខាសៀមរាប**

អគារលេខ 29 និង 30
ផ្លូវហ្សាលដឺហ្គោល សាលាកន្សែង សង្កាត់ស្វាយដង្គំ ទីរួមខេត្តសៀមរាប

**សាខាបាត់ដំបង**

ផ្ទះលេខ 2-6ផ្លូវលេខ 3 ភូមិកម្មករ សង្កាត់ស្វាយប៉ោ ក្រុងបាត់ដំបង ខេត្តបាត់ដំបង

**សាខាកំពង់ចាម**

ភូមិ 15 សង្កាត់កំពង់ចាម ខណ្ឌកំពង់ចាម ខេត្តកំពង់ចាម

**សាខាកំពត**

ផ្លូវលេខ 700 ភូមិ 1ឧសភា សង្កាត់កំពង់កណ្តាល ក្រុងកំពត ខេត្តកំពត

086 999 242 | AIA.COM.KH | AIA CAMBODIA